ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០៤២៨ រ.ថ.អប្រក.ប្រក

# ប្រកាស
## ស្តីពី
## លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ
## លេខ ០៤២៨ រថ.អប្រក.លអ ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ២០២២

## រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល


លេខ ១ មហាវិថីព្រះនរោត្តម សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤
#1, Preah Norodom Blvd, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 www.mme.gov.kh info@mme.gov.kh

ឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១ របស់លោក **លី ធានឡាយ**
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល

## សម្រេច

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្ដល់លិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ មានស្លាកយីហោឈ្មោះ **ដេប៉ូតេលា ឧសភា ដាលីន** ស្ថិតនៅភូមិគូលែនត្បូង ឃុំគូលែនត្បូង ស្រុកគូលែន ខេត្តព្រះវិហារ របស់លោក **លី ធានឡាយ (ម្ចាស់ស្ថានីយ)**។

**ប្រការ២.-**

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

**ប្រការ៣.-**

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមប្រកាសលេខ០១៤១រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែ និងថាមពល ដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោម ក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

- លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- លិខិតអនុញ្ញាតទីតាំងពីអាជ្ញាធរដែនដី។

**ប្រការ៤.-**

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមសារាចរលេខ០១៤០រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល ដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះនូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. មិនអនុញ្ញាតឱ្យមានលំនៅដ្ឋានក្នុងបរិវេណស្ថានីយ

២. មិនអនុញ្ញាតឱ្យដាក់អីវ៉ាន់ក្នុងបរិវេណស្ថានីយដោយគ្មានសណ្ដាប់ធ្នាប់

៣. ត្រូវមានឃ្លុបការពារកបំពង់ទទួលប្រេងឥន្ធនៈ

៤. កបំពង់ទទួលប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៣ម៉ែត្រ ពី របងព្រំដីស្ថានីយ

៥. បំពង់ខ្យល់ប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ២ម៉ែត្រ ពី របងព្រំដីស្ថានីយ
៦. ត្រូវមានរបាំងការពារបំពង់ខ្យល់ប្រេងឥន្ធនៈពីការប៉ះទង្គិច
៧. ទុយោចាក់ប្រេងឥន្ធនៈមិនត្រូវមានប្រវែងលើស ពី៦ម៉ែត្រ
៨. ត្រូវបំពាក់គន្លឹះអាសន្ននៅតាមទូចាក់ប្រេងឥន្ធនៈនីមួយៗ និងគន្លឹះអាសន្នរួម
៩. ត្រូវមានគំនូសសញ្ញាចំណតសម្រាប់រថយន្តស៊ីទែនផ្ទេរប្រេងឥន្ធនៈ
១០. ត្រូវមានស្លាកសញ្ញាបម្រាមស្តីពីសុវត្ថិភាពឱ្យបានគ្រប់គ្រាន់
១១. ត្រូវមានផ្ទាំងព័ត៌មានស្តីពីនីតិវិធីនៃការផ្ទេរប្រេងឥន្ធនៈ
១២. ត្រូវមានប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក
១៣. ត្រូវសង់របងជញ្ជាំងធ្វើពីវត្ថុធាតុមិនឆាបឆេះ និងកំពស់អប្បបរមា ៣ម៉ែត្រ បាំងជិតនៅព្រំដីស្ថានីយដែលនៅជាប់នឹងព្រំដីលំនៅដ្ឋាន។

**ប្រការ៥.-**

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ៦.-**

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

**ប្រការ៧.-**

ម្ចាស់ស្ថានីយត្រូវផ្តល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

**ប្រការ៨.-**

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធភាពខ្ពស់។

**ប្រការ៩.-**

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

**ប្រការ១០.-**

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពលរយៈពេល ១ (មួយ) ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

**ប្រការ១១.-**

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយ លេខ០៤២៨ រ៉ែ.អបក.ឈអ...........ចុះថ្ងៃទី...២៤...............ខែ...មិថុនា........ឆ្នាំ២០២២ របស់ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១២.-**

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើ នោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ..០៤២៨ រ៉ែ.អបក.ឈអ ចុះថ្ងៃទី.....២៤.....ខែ.....មិថុនា.....ឆ្នាំ២០២២ នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

**ប្រការ១៣.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយក នៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែ និងថាមពលខេត្តព្រះវិហារ និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ.សុក្រ...១០រោច.ខែ..ជេស្ឋ..ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..២៤.ខែ..មិថុនា..ឆ្នាំ២០២២
**រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**

**ស៊ុយ សែម**

<u>**កន្លែងទទួល:**</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តព្រះវិហារ
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ